អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២**

# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងស្ថានភាពនៃសំណុំរឿងលេខ004

យោងតាមវិធាន ៥៤ នៃវិធានផ្ទៃក្នុងរបស់ អវតក សហព្រះរាជអាជ្ញាជាតិ សូមធ្វើសេចក្តីប្រកាសព័ត៌មានជាសាធារណៈទាក់ទងនឹងស្ថានភាពនសំណុំរឿងលេខ 00៤ ដែលមានជនជាប់ចោទឈ្មោះ យឹម ទិត្យ ដូចខាងក្រោម៖

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចប្រកាសបញ្ចប់សំណុំរឿងលេខ 00៤ ដោយមូលហេតុគ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបាន។
នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ សហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ បានសម្រេចជាឯកច្ឆ័ន្ទចេញដីកាបង្គាប់អោយបញ្ចូលសំណុំរឿងលេខ 00៤ ទៅក្នុងបណ្ណសារដ្ឋាន។

សហព្រះរាជអាជ្ញាជាតិ សូមបញ្ជាក់ថា យោងតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងយោងតាមច្បាប់ស្តីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានផ្តល់សមត្ថកិច្ចដល់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តែមួយគត់ក្នុងការកាត់សេចក្តីលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធទៅនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩។

***សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖***

លោក **នេត្រ ភក្ត្រា**
ប្រធានផ្នែកកិច្ចការសាធារណៈនិងជាអ្នកនាំពាក្យ
ទូរស័ព្ទចល័ត+៨៥៥(0)១២ ៤៨៨ ១៥៦
អ៊ីមែល៖ neth.phektra@eccc.gov.kh